# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៧

## ស្តីពី

## ការកំណត់រមណីយដ្ឋានប្រាសាទបន្ទាយឆ្មារ

*****

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## សម្រេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទបន្ទាយឆ្មារ ជារមណីយដ្ឋានការពារ ស្ថិតនៅក្នុងភូមិបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ក្នុងខេត្តបន្ទាយមានជ័យ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកតំលៃរមណីយដ្ឋានការពារ ឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទបន្ទាយឆ្មារ ត្រូវចាត់ជា ៣ ( បី ) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - តំបន់ទី ១ : ជាតំបន់រមណីយដ្ឋានប្រាសាទ ហៅថា **តំបន់ស្នូល** មានផ្ទៃក្រឡា ៩១.៤៨ហិកតា ស្ថិតក្នុងបរិវេណនិយាមការ នៃចំណុចខ្សែបន្ទាត់ព្រំប្រទល់

$A_1$ ( 294409 ; 1556780 ) , $C_1$ ( 295304 ; 1555994 )
$B_1$ ( 294437 ; 1555950 ) , $D_1$ ( 295300 ; 1556808 )

ដែលជាខ្សែបន្ទាត់នៅក្រៅប្រឡាយប្រវត្តិសាស្ត្រ ហើយជាអ័ក្សផ្លូវព័ទ្ធជុំវិញប្រាសាទ ។
តំបន់នេះជាតំបន់មានប្រាសាទបន្ទាយឆ្មារ សំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - តំបន់ទី ២ : ជាតំបន់ឧទ្យានបុរាណវត្ថុ ហៅថា **តំបន់ទ្រនាប់** មានផ្ទៃក្រឡា ៧៧៩.៩៥ហិកតា ស្ថិតក្នុងចន្លោះបរិវេណនិយាមការនៃចំណុច $A_1$ $B_1$ $C_1$ $D_1$ និង បរិវេណនិយាមការនៃចំណុច

| | | | |
|---|---|---|---|
| $A_2$ | ( 294560 ; 1557822 ) | $I_2$ | ( 294560 ; 1555276 ) |
| $B_2$ | ( 294560 ; 1557560 ) | $J_2$ | ( 294560 ; 1555074 ) |
| $C_2$ | ( 293698 ; 1557532 ) | $K_2$ | ( 296148 ; 1555102 ) |
| $D_2$ | ( 293698 ; 1556644 ) | $L_2$ | ( 296148 ; 1555925 ) |
| $E_2$ | ( 293038 ; 1556653 ) | $M_2$ | ( 297872 ; 1555925 ) |
| $F_2$ | ( 293038 ; 1556135 ) | $N_2$ | ( 297872 ; 1557140 ) |
| $G_2$ | ( 293698 ; 1556140 ) | $O_2$ | ( 296148 ; 1557134 ) |
| $H_2$ | ( 293698 ; 1555291 ) | $P_2$ | ( 296148 ; 1557822 ) |

តំបន់នេះជាឧទ្យានសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការការពារទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍមិនសមស្រប ។

គ - តំបន់ទី ៣ : ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់រណប ដោយរក្សាជីវភាពមុខរបរ អាជីវកម្ម តាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះ ស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការនៃចំណុច $A_2$ $B_2$ $C_2$ $D_2$ $E_2$ $F_2$ $G_2$ $H_2$ $I_2$ $J_2$ $K_2$ $L_2$ $M_2$ $N_2$ $O_2$ $P_2$ ចម្ងាយ ១.៥០០ម៉ែត្រ ។
តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍន៍ឱ្យមានចីរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទបន្ទាយឆ្មារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណោតថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង កំរិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ទ្រព្យសម្បត្តិជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្ដាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្ដីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦។

របៀបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានប្រាសាទបន្ទាយឆ្មារក្នុងបណ្ដាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទបន្ទាយឆ្មារ អាចពិនិត្យឡើងវិញហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្ដែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាពដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទបន្ទាយឆ្មារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ដោយផ្អែកតាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមីនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ០៣ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]


A- 294560, 1557822
C- 293690, 1557532
E- 293038, 1556653
F- 293038, 1556135
K- 296148, 1555102
M- 297372, 1555825
N- 297372, 1557140
P- 296148, 1557822
1500m